ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ: ០៦៤/១៦ ក.ជ.ក

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមេសា និងទិសដៅខែ ឧសភា ឆ្នាំ ២០១៦

( គិតចាប់ពីថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៦ ដល់ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៦ )

## I.ស្ថានភាពទូទៅ

នៅក្នុងខែមេសា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបំពេញតួនាទីតាមមុខងាររបស់ខ្លួនដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ដោយមានកិច្ចសហប្រតិបត្តិការរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ រួមទាំងអង្គការក្រៅរដ្ឋាភិបាលជាដៃគូជាតិនិងអន្តរជាតិ។

អំពីសភាពការណ៍បទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយផ្អែកតាមរបាយការណ៍ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ បានរកឃើញបទល្មើសជាច្រើនករណី តាមទម្រង់ផ្សេងៗដូចជាការធ្វើអាជីវកម្មផ្លូវភេទ សព្វារកម្ម និងទេសន្តរប្រវេសន៍ស្វែងរកការងារ ការស្វែងរកគូស្រករនៅក្រៅប្រទេស ។ ក្នុងចំណោមជនទេសន្តរប្រវេសន៍ ដែលកំពុងនៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់ ត្រូវបានរងគ្រោះជាបន្តបន្ទាប់ និងត្រូវបានបញ្ជូនមកកម្ពុជាវិញ ហើយមួយចំនួនបានត្រឡប់មកផ្ទះវិញដោយខ្លួនឯង និងខ្លះទៀតបាត់ដំណឹង ។ កត្តាទាំងអស់នេះ ជាបញ្ហាប្រឈម ដែលគណៈកម្មាធិការជាតិ គ.ជ.ប.ជ ត្រូវរួមសហការជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិក និង អង្គភាពដែលពាក់ព័ន្ធ ត្រូវព្យាយាមបង្ការទប់ស្កាត់ និងដោះស្រាយបញ្ហារួមគ្នា ។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញការសម្របសម្រួល ជាមួយក្រុមការងារ អន្តរក្រសួង ស្ថាប័ន ព្រមទាំងរាជធានី-ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមនានា សុំឲ្យមានការស្រាវជ្រាវស៊ើបអង្កេតបទល្មើស និងសិក្សាពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ។ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបំពេញតួនាទី និងភារកិច្ចយ៉ាងមមាញឹក ខិតខំប្រឹងប្រែងបន្តអនុវត្តយុទ្ធវិធី តាមផែនការសកម្មភាពជាតិ ឆ្នាំ២០១៤-២០១៨ ដើម្បីបន្តសកម្មភាពក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងជំរុញការដឹកនាំ ស្តីពីការបង្ការ បង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការដាក់ទណ្ឌកម្ម លើជនល្មើស ។

របាយការណ៍ខាងក្រោម ជាទិន្នន័យដែលទទួលបានពីក្រុមការងារអនុវត្តន៍ច្បាប់ចំនួន០១ច្បាប់ ដែលដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ និងរាជធានី/ខេត្ត ចំនួន២៤ច្បាប់ គឺ (រាជធានីភ្នំពេញ ,ខេត្ត កោះកុង ,ព្រះសីហនុ ,កំពត , កែប ,តាកែវ , កំពង់ស្ពឺ , កំពង់ឆ្នាំង ,កណ្តាល , ស្វាយរៀង ,ព្រៃវែង ,ពោធិ៍សាត់ ,ប៉ៃលិន ,បាត់ដំបង ,បន្ទាយមានជ័យ , ឧត្តរមានជ័យ ,ព្រះវិហារ , សៀមរាប ,កំពង់ធំ , ក្រចេះ ,រតនគិរី ,មណ្ឌលគិរី ,ត្បូងឃ្មុំ និងខេត្តកំពង់ចាម) និងសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលទទួលបានលទ្ធផល ដូចខាងក្រោម ៖

## II.លទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

នៅក្នុងខែមេសា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានបន្តយកចិត្តទុកដាក់អនុវត្តផែនការសកម្មភាព និងទិសដៅភារកិច្ចរបស់ខ្លួន ដោយពង្រឹងកិច្ចសហប្រតិបត្តិការ រវាងបណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បានធ្វើឲ្យសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

### ក. ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស

#### ១. ការងារបង្ការ-ទប់ស្កាត់:

#### ១.១.ការផ្សព្វផ្សាយ អប់រំ

នៅក្នុងខែមេសា ឆ្នាំ២០១៦នេះ ការផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធអាជ្ញាធរ និងសមត្ថកិច្ច បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយជាសាធារណៈ ទៅតាមគោលដៅចំនួន១,៤១៤លើក បើប្រៀបធៀបខែមុនមានចំនួន៩៧៧លើក មានការកើនឡើងចំនួន៤៣៧លើក ស្មើនឹង៤៤,៧២% និងមានមនុស្សចូលរួមសរុបចំនួន១៥២,៦៦៥នាក់ បើប្រៀបធៀបខែមុនមានចំនួន៨១,៩៨៥នាក់ មានការកើនឡើងចំនួន៧០,៦៨០នាក់ ស្មើនឹង៨៦,២១% ក្នុងនោះស្ត្រីមានចំនួន៧៤,៤៨២នាក់។ (ឧបសម្ព័ន្ធទី១)

#### ១.២.ការងារបង្ការ-ទប់ស្កាត់

យោងលើលទ្ធផលសម្រេចបាន លើការងារបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស ដែលនាយកដ្ឋានជំនាញសមត្ថកិច្ច កងរាជអាវុធហត្ថ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សហការជាមួយស្ថាប័នពាក់ព័ន្ធ ទទួលបានលទ្ធផលសរុបចំនួន០៩លើក បើប្រៀបធៀបខែមុនមានចំនួន១៨លើក មានការថយចុះចំនួន០៩លើក ស្មើនឹង៥០% មានមនុស្សចំនួន១១៥នាក់ បើប្រៀបធៀបខែមុនមានចំនួន៣១៩នាក់ មានការថយចុះចំនួន២០៤លើក ស្មើនឹង៦៣,៩៤% ក្នុងនោះស្ត្រីចំនួន៣៩នាក់ ។ (ឧបសម្ព័ន្ធទី២)

○ ស្នងការដ្ឋាននគរបាលខេត្តតាកែវ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យា ហាមឃាត់ ការប្រព្រឹត្តអំពើសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារក្នុងហាងម៉ាស្សា, ខារ៉ាអូខេ បានចំនួន១២២គោលដៅ និងមានមនុស្សចំនួន៤១០នាក់ (ស្រីចំនួន៤០៥នាក់) ។

○ បច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ទាំង២៥ រាជធានី-ខេត្ត មានចំនួន៧០គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន០៥គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៥គោលដៅ ។

○ ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន៧៩កន្លែងស្មើនឹង៧៩គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន៤១៨នាក់ ស្រីចំនួន២២១នាក់ ។

○ ស្នងការដ្ឋាននគរបាលខេត្តកែប បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុប១៤គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន១៥០នាក់ ស្រីចំនួន១២៥នាក់ ។

○ ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន១២៣កន្លែងស្មើនឹង១២៣គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន៩៥៣នាក់ ស្រីចំនួន៥៩២នាក់ ។

○ ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះផ្ទះសម្នាក់, ផ្ទះដួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន០៨កន្លែងស្មើនឹង០៨គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

○ ស្នងការដ្ឋាននគរបាលខេត្តសៀមរាប

- បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសម្នាក់, ផ្ទះដួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន៩៣គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។
- ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមផ្សព្វផ្សាយ ស្តីពីច្បាប់ពាក់ព័ន្ធអំពើជួញដូរមនុស្ស តាមវិទ្យុបានចំនួន០៤លើក ។
- មន្ទីរព័ត៌មានខេត្តសៀមរាប បានសហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និងអង្គភាពពាក់ព័ន្ធ ចូលរួមធ្វើជាវាគ្មិន ដើម្បីផលិតកម្មវិធីសន្ទនាមតិ និងកម្មវិធីយើងធ្វើបាន ផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយខុសច្បាប់ ការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលក្នុងខេត្ត ។

## ២. ការងារការពារ ស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍

### ២.១ ការងារការពារ-ស្តារនីតិសម្បទាជនរងគ្រោះ

គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មសរុបបានចំនួន**៤៤**នាក់ បើប្រៀបធៀបខែមុនមានចំនួន**១០៣**នាក់ មានការថយចុះចំនួន**៥៩**នាក់ **ស្មើនឹង៥៧,២៨%** ក្នុងនោះស្ត្រី មានចំនួន**៣២**នាក់។

+ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ បានទទួលនារីរងគ្រោះដោយការធ្វើអាជីវកម្មផ្លូវភេទចំនួន**១៧**នាក់ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងបានទទួលឲ្យស្នាក់នៅមណ្ឌលសំចតរបស់មន្ទីរសង្គមកិច្ច រាជធានីភ្នំពេញ ។
+ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង បានទទួលប្រជាជនឆ្លងដែនខុសច្បាប់ទៅប្រកបរបរលក់ឆ្នោត សុំទាន និងធ្វើការកសិដ្ឋាន នៅប្រទេសវៀតណាមចំនួន០១លើក មានចំនួន១០គ្រួសារ មនុស្សចំនួន**២៧**នាក់ ស្រីចំនួន**១៥**នាក់ (តាមច្រកទ្វារអន្តរជាតិបាវិត) ។

### ២.២ សមាហរណកម្ម និងមាតុភូមិនិវត្តន៍: ក្នុងខែមេសា ឆ្នាំ ២០១៦

ស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត បានទទួល និងសម្ភាសពលករទេសន្តប្រវេសន៍ ដែលអាជ្ញាធរម៉ាឡេស៊ីបញ្ជូនមក និងអាជ្ញាធរវៀតណាមបញ្ជូនមកវិញ ក្នុងខែមេសា ឆ្នាំ២០១៦ ក្រោយធ្វើការសម្ភាសរួច ពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំ ឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។ (**ឧបសម្ព័ន្ធទី៤**)

### ២.៣ ការងារទទួលពលករខ្មែរពីអាជ្ញាធរបរទេស:

ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យ និងខេត្តស្វាយរៀង បានទទួលការសម្ភាសពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនមកវិញ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារអន្តរជាតិបាវិត មានចំនួន៦,១៤៣នាក់(ស្រីចំនួន២,០៧៨នាក់) អនីតិជនចំនួន៥១៤នាក់ (ស្រីចំនួន២១១នាក់) ។

- ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យមានចំនួន៦,១១២នាក់ (ស្រីមានចំនួន២,០៦២នាក់) អនីតិជនចំនួន៤៩៤នាក់ (ស្រីចំនួន២០៣នាក់) ។
- ស្នងការដ្ឋាននគរបាលខេត្ត ស្វាយរៀង មានចំនួន៣១នាក់ (ស្រីមានចំនួន១៦នាក់) អនីតិជនចំនួន២០នាក់ (ស្រីចំនួន០៨នាក់) ។

-មានប្រជាពលរដ្ឋខ្មែរចំនួន២៨នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែ មុនបញ្ជូនមកកម្ពុជាវិញ ក្រោយធ្វើការសម្ភាសរួច ពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

### ៣. ការងារអនុវត្តច្បាប់

-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស

នាយកដ្ឋានជំនាញ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដាន ស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន០៦ករណី/០៥ករណី(បើប្រៀបធៀប ខែមុនកើន០១ករណី)ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន០៦នាក់ (ស្រីចំនួន០៤នាក់)(ក្នុងនោះជនជាតិឥណ្ឌាចំនួន០១នាក់) សង្គ្រោះជនរងគ្រោះបានចំនួន២៥នាក់ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន០២នាក់ ,អាយុពី១៥-១៧ឆ្នាំចំនួន០២នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន២១នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន២០នាក់ និងចំនួន០៥នាក់ទៀត ប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ )។

➢ **អំពើធ្វើអាជីវកម្មផ្លូវភេទ:**

សរុបចំនួន០៥ករណី/០៦ករណី ជនសង្ស័យចំនួន០៥នាក់(ស្រី០២នាក់)ជនរងគ្រោះចំនួន១៦នាក់ អាយុក្រោម១៥ឆ្នាំចំនួន០២នាក់ ,អាយុពី១៥-១៧ឆ្នាំចំនួន០៥នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន០៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន១២នាក់ និងចំនួន០៤នាក់ ទៀតប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ ) ។

| | |
|---|---|
| -សញ្ជារកម្ម | ០២ករណី ជនសង្ស័យ ០២នាក់ |
| -សញ្ជារកម្ម ( ទាក់ទងនឹងពេស្យាចារកុមារ ) | ០២ករណី ជនសង្ស័យ ០២នាក់ |
| -អំពើអាសប្រទាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ករណី ជនសង្ស័យ ០២នាក់ |

### ៤. ការងារកិច្ចការយុត្តិធម៌

តាមទិន្នន័យដែលបានទទួលពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត ការងារផ្តន្ទាទោស នៅក្នុងខែមេសា ឆ្នាំ២០១៦នេះ តុលាការរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មិនទាន់បានបូកសរុបលទ្ធផលនៅឡើយ ។

### ៥. ការងារសហប្រតិបត្តិការអន្តរជាតិ

+គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ្មាន)

+ខេត្ត ប៉ៃលិន ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ បានសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលដល់ក្រុមហ៊ុន WIN-WIN MANPOWER SERVICE CO. LTD ដែលបានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ចំនួន០១លើក មានពលករចំនួន០៨នាក់ ស្រីចំនួន០៥នាក់ ។

### ៦. ការងារពាក់ព័ន្ធនឹងកុមារ

សកម្មភាពខិតខំប្រឹងប្រែង ក្នុងកិច្ចការការពារ និងជួយសង្គ្រោះដល់កុមារ ជាពិសេសកុមារងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មរបស់គ.រ.ប.ជ/គ.ខ.ប.ជ សរុបបានចំនួន១៨នាក់ ក្នុងនោះជាកុមារីចំនួន០៩នាក់ ៖

+ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រចេះ បានទទួលកុមាររងគ្រោះដោយការធ្វើអាជីវកម្មផ្លូវភេទ០៩នាក់(កុមារី)ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស បានទំនាក់ទំនងបញ្ជូនពួកគេឲ្យទៅទទួលសេវាថែទាំព្យាបាលជំនួស នៅអង្គការមេត្រីអន្តរជាតិ ចំនួន០៦នាក់ និងអង្គការកម្ពុជាដើម្បីជួយដល់ស្ត្រីមានវិបត្តិ០៣នាក់ ។

+ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកណ្តាល បានទទួលកុមាររងគ្រោះដោយការធ្វើអាជីវកម្មផ្លូវភេទ០៩នាក់ ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស បានទំនាក់ទំនងបញ្ជូនពួកគេឲ្យទៅទទួលសេវាថែទាំព្យាបាលជំនួស នៅអង្គការមេត្រីអន្តរជាតិ ចំនួន០៦នាក់ និងអង្គការកម្ពុជាដើម្បីជួយដល់ស្ត្រីមានវិបត្តិ ០៣នាក់ ។

### ៧. ការងារទេសន្តរប្រវេសន៍

○ តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើការសម្ភាសពលករខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍បានចំនួន១០៦គូ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលបានរៀបការរួចទៅនៅឯក្រៅប្រទេស ដោយបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់របស់សាមីខ្លួនបានចំនួន២០នាក់ (រស់នៅជាមួយគ្រួសារមានសេចក្តីសុខសប្បាយជាធម្មតា) ព្រមទាំងបានសម្ភាសពលករ ពលការិនីរងគ្រោះក្នុងនោះមាន ៖

តាមទិន្នន័យរបស់នាយដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែមេសា ឆ្នាំ២០១៦ សរុបបានចំនួន២៩១,០៨៤នាក់(ស្រីចំនួន៦១,៩០៩នាក់) អនីតិជន មានចំនួន៦,០៧០នាក់ (ស្រីចំនួន២,៣៩១នាក់) ក្នុងនោះស្របច្បាប់ចំនួន១៥៤,០០៧នាក់ (ស្រីចំនួន២,៣៩១នាក់) និងអនីតិជនចំនួន៨៣៨នាក់ (ស្រីចំនួន៣៦៣នាក់) មិនស្របច្បាប់ចំនួន១៣៧,០៧៧នាក់ (ស្រីចំនួន៥៩,៥១៨នាក់) និងអនីតិជនចំនួន៥,២៣២នាក់ (ស្រីចំនួន២,០២៨នាក់) ។

## ខ.ការងារដឹកនាំសម្របសម្រួល

ការងារដឹកនាំសម្របសម្រួលសរុបរួមបានចំនួន៦៧លើក ក្នុងខែមេសា ឆ្នាំ២០១៦ ដែលធ្វើឡើងដោយគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងគណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ ។ (**ឧបសម្ព័ន្ធទី៧**)

### +សកម្មភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

- បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងពិធីសម្ពោធគម្រោង "**លើកកម្ពស់សិទ្ធិកុមារក្នុងអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា**" រៀបចំដោយអង្គការ Save the Children នៅសណ្ឋាគារ Imperial Garden ព្រឹកថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំជាមួយលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តបន្ទាយមានជ័យ នៅសាលាខេត្តបន្ទាយមានជ័យ ក្នុងគោលបំណងតាមដាន សកម្មភាពការងារ និងពិនិត្យស្ថានភាពប្រែប្រួលនៃលំហូរទេសន្តរប្រវេសន៍ ការគ្រប់គ្រងការបញ្ជូនចេញ-ចូល ការទទួលជនរងគ្រោះ និងស្ថានភាពមណ្ឌលសំចត និងមណ្ឌលដៃគូពាក់ព័ន្ធ និងបានដឹកនាំគណៈប្រតិភូ(គ.ខ.ប.ជ) ទៅធ្វើទស្សនកិច្ចនៅមណ្ឌលសំចតប៉ោយប៉ែត ។ បន្ទាប់មកគណៈប្រតិភូបានជួបប្រជុំ ជាមួយមន្ត្រីមានសមត្ថកិច្ចនៅស្នាក់ការច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក្នុងគោលបំណងស្តាប់ របាយការណ៍ និងស្វាបស្ទង់អំពីស្ថានភាពអន្តោប្រវេសន៍ការចេញ-ចូល និងបញ្ជូនត្រឡប់នូវពលករកម្ពុជាតាមច្រកទ្វារអន្តរជាតិនិងច្រករបៀងនានា ថ្ងៃទី០៤-០៦ ខែមេសា ឆ្នាំ២០១៦ ។
- បានអញ្ជើញជាអធិបតីក្នុងវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុក និងអំពើជួញដូរមនុស្ស នៅភូមិស្រែបេង ភូមិជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ដោយមានការចូលរួមពីកងកម្លាំងមានសមត្ថកិច្ច ប្រជាការពារ និងប្រជាពលរដ្ឋប្រមាណ ៥០០នាក់ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយ អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ លើសេចក្តីព្រាងអនុស្សរណៈរវាងប្រទេសកម្ពុជា និងប្រទេសឥណ្ឌា ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការពិនិត្យលើផែនការនៃការចុះស្រាវជ្រាវ អំពីពលករចំណាកស្រុក ជាមួយអង្គការដៃគូអភិវឌ្ឍន៍រួមមាន Winrock, IOM និង Cambodia Acts, នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ ។

- បានដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យ ពិភាក្សា និងកែតម្រូវតារាងតាមដាន សន្ទស្សន៍អនុវត្តន៍ផែនការថ្នាក់ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០១៤-២០១៨ ជាមួយអង្គការដៃគូអភិវឌ្ឍន៍រួមមាន Winrock, GVC, Chab Dai និង Cambodia Acts នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និងជនបរទេស នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ។

## ឃ. ការលើកកម្ពស់សមត្ថភាព

### ១.ការបណ្តុះបណ្តាល

+ ខេត្តកំពង់ស្ពឺ

- ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលស្រុកសំរោងទង បានបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារបានចំនួន០១លើក ដែលមានការចូលរួម ពីមេឃុំក្រុមប្រឹក្សាឃុំ មេប៉ុស្តិ៍ មន្ត្រីមកពីស្ថាប័នពាក់ព័ន្ធ និងយុវជននៅភូមិ ឃុំជ្ញាយ ស្រុកសំរោងទង សរុបចំនួន៥០នាក់ ស្រីចំនួន១៦នាក់ ។

### ២. សិក្ខាសាលា

+ **ខេត្តតាកែវ** បានរៀបចំសិក្ខាសាលាបណ្តាញភូមិ ឃុំមានសុវត្ថិភាព ស្តីពីវិធានការទប់ស្កាត់ និងការពារអំពើជួញដូរមនុស្ស ចំនួន០១លើក មានអ្នកចូលរួមចំនួន៥០នាក់ ស្រីចំនួន១៩នាក់ គាំទ្រដោយអង្គការ VCAO ។

## III. ការវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង ក្នុងខែមេសា ឆ្នាំ២០១៦នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចបានការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

១. បានប្រកាសជាផ្លូវការ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គណៈកម្មាធិការរាជធានី-ខេត្តគ.រ.ប.ជ/គ.ខ.ប.ជ លេខាធិការដ្ឋានគ.រ.ប.ជ/គ.ខ.ប.ជ ប្រកាសសេចក្តីសម្រេចកំណត់តួនាទី ភារកិច្ចរួមជាស្រេច។

២. បានដាក់ចុះផែនការសកម្មភាពជាតិរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រាប់រយៈ ពេល៥ ឆ្នាំ (២០១៤-២០១៨) ជាផែនទីបង្ហាញផ្លូវ ។

៣. បានរៀបចំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងបន្តសកម្មភាពដឹកនាំជាយុទ្ធសាស្ត្រ របស់ក្រុមការងារទាំង៦ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា លើកវិធានការ ការងារបង្ការទប់ស្កាត់និង បង្ក្រាបបទល្មើសជួញដូរមនុស្ស ។

៤. បានបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយអន្តរក្រសួង ស្ថាប័ននានា ក្នុងដំណើរការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់។

៦. បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។

### ខ.ចំណុចសេសសល់ និងភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ក្រុមការងារអន្តរក្រសួងស្ថាប័ន ព្រមទាំងលេខាធិការដ្ឋានរាជធានី-ខេត្ត មួយចំនួនមិនទាន់ផ្ញើរបាយការណ៍ប្រចាំខែបានតាមការកំណត់ របស់ គ.ជ.ប.ជ នៅឡើយ ។

- ត្រូវពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តបន្ថែមទៀត ដោយមូលហេតុមានការផ្លាស់ប្តូរ សមាសភាព និងការរៀបចំជាថ្មីនូវរចនាសម្ព័ន្ធតាមបណ្តាថ្នាក់ ។
- សមត្ថភាព និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់នៅមានកម្រិត ដែលទាមទារឲ្យពង្រឹងបន្ថែម ទើបអាចឆ្លើយតបទៅនឹងសភាពការណ៍នៃបទល្មើស ។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ ក្នុងនោះមានជនរងគ្រោះ នៅមិនទាន់ឆ្លើយតបទាន់សភាពការណ៍ ។
- ការទទួលព័ត៌មាន និងការអប់រំ ផ្សព្វផ្សាយ អំពីកលល្បិចរបស់ជនខិលខូចនៅមិនទាន់បានទូលំទូលាយនៅឡើយ សម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទដាច់ស្រយ៉ាលដែលជាចំណុចចន្លោះប្រហោងមួយសម្រាប់ពួកឈ្មួញទុច្ចរិតធ្វើការអូសទាញ បោកបញ្ឆោតទាំង បុរស ស្ត្រី និងកុមារ ឲ្យជឿជាក់ និងធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ ។
- ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការខ្វះខាត ហើយចំណេះដឹងនិងការអប់រំ របស់ពួកគាត់នៅមានកម្រិតដូច្នេះ ទើបធ្វើឲ្យពួកគាត់ ធ្វើការសម្រេចចិត្តរួសរាន់ទៅតាមការអូសទាញរបស់ឈ្មួញទុច្ចរិត។
- រចនាសម្ព័ន្ធ នៃគណៈកម្មាធិការរាជធានី/ខេត្ត និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន មិនទាន់បានរៀបចំត្រឹមត្រូវច្បាស់លាស់ ក្នុងការធ្វើការតាមដានការងារជាប្រចាំ និងពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយលើការងារថ្នាក់ក្រោមជាតិ ។
- អង្គការជាតិ និងអន្តរជាតិមួយចំនួន នៅមិនទាន់ចូលរួមពេញលេញក្នុងការអនុវត្តយន្តការ និងសកម្មភាពរួមនេះ ហើយបានធ្វើសកម្មភាពដោយឡែក ដែលមិនឆ្លើយតបនឹងគោលដៅ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

## IV.ទិសដៅសម្រាប់ខែឧសភា ឆ្នាំ ២០១៦

១. ជំរុញការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ០៤ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៥ នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ និង គោលការណ៍ណែនាំរបស់រាជ រដ្ឋាភិបាល លេខ០០១ គកន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍ ។

២. បន្តជំរុញអនុវត្ត វិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៣. រៀបចំសកម្មភាពវាយតម្លៃផែនការសកម្មភាពជាតិ ២០១៤-២០១៨ ពាក់កណ្តាលអណត្តិ និងកែលម្អសកម្មភាពជំហានបន្តរហូតដល់ឆ្នាំ២០១៨ ។

៤. រៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធ នឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ តាមបណ្តាក្រសួង មន្ទីរ ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ និងជំរុញការអនុវត្តបន្ត ។

៥. ត្រៀមសេចក្តីព្រាងផែនការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-ចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៦. ធ្វើការស្រាវជ្រាវ អំពីកាលានុវត្តភាពការងារជាជម្រើសរបស់ពលករកម្ពុជាក្នុងនិងក្រៅប្រទេស និងស្វែងយល់ពីកត្តារុញច្រាន និងអូសទាញ ដើម្បីរៀបចំផែនការបង្ការទប់ស្កាត់ ។

៧. ត្រៀមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ដើម្បីពិនិត្យសម្រេចលើសេចក្តីព្រាង កិច្ចព្រមព្រៀង ដែលបានឯកភាពគ្នាជាគោលការណ៍រួចហើយ កាលពីជំនួប នៅប្រទេសចិន នាខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ត្រៀមពិនិត្យ កិច្ចព្រមព្រៀង ទ្វេភាគី កម្ពុជា-ឥណ្ឌា តាមការស្នើសុំរបស់ រដ្ឋាភិបាលឥណ្ឌា ។

៩. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល( ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការដើម្បីចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ និយោជក និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ប្រកបដោយសមធម៌ ។

១០. បន្តពង្រឹងកិច្ចសហការទូលំទូលាយ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា ។

១១. ជំរុញការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ទៅតាមមុខសញ្ញានៃក្រសួង ស្ថាប័ន និងអង្គភាពដែលទទួលខុសត្រូវ ឈានទៅធ្វើឲ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

១២. សម្របសម្រួល ពង្រឹង និងពង្រីកកិច្ចសហការឲ្យបានទូលំទូលាយជាមួយគ្រប់ផ្នែក គ្រប់វិស័យ និង រវាងរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដើម្បីអនុវត្ត យុទ្ធសាស្ត្រដែលបានគ្រោងទុកក្នុងផែនការជាតិ ផែនការរបស់ក្រុមការងារទាំងប្រាំមួយ និងផែនការរាជធានី/ខេត្ត ។

១៣. គាំទ្រ និងពង្រឹងសមត្ថភាព របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត ។

១៤. បន្តការងារផ្សព្វផ្សាយ អប់រំ តាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការ យល់ដឹងជាសកល អំពីអំពើការជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ និងជនដែលងាយរងគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ
  "ដើម្បីគោរពជូនជារបាយការណ៍"
- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# ឧបសម្ព័ន្ធទី៤

## តារាងតួលេខប្រាគុភាពជនរងគ្រោះ នៅក្រៅប្រទេស ចាប់ពី ថ្ងៃទី២៦ ខែ មីនា ឆ្នាំ២០១៦ ដល់ ថ្ងៃទី២៥ ខែមេសា សំរាប់ប្រចាំខែមេសា ឆ្នាំ២០១៦

| ល.រ | បញ្ជូនមកពីប្រទេស | សរុបរួម | មុខរបរ | | | | | | ត្រឡប់មកផ្ទះវិញតាមរយៈ | | | ទៅតាមរយៈ | | | ដំណោះស្រាយ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | នេសាទ | បំរើតាមផ្ទះ | អាពាហ៍ពិពាហ៍ | សុំទាន | ពលករ | ផ្សេងៗ | IOM | ការបរទេស | ផ្សេងៗ | មេខ្យល់ | ក្រុមហ៊ុន | ខ្លួនឯង | បង្ក្រាប | | បញ្ជូនសំណុំរឿង | | សងសំណង | |
| | | | | | | | | | | | | | | | ក | ជ.គ | ក | ជ.គ | ក | ជ.គ |
| 1 | ឥណ្ឌូនេស៊ី | | | | | | | | | | | | | | | | | | | |
| 2 | ថៃ | | | | | | | | | | | | | | | | | | | |
| 3 | អាហ្វ្រិកខាងត្បូង | | | | | | | | | | | | | | | | | | | |
| ៤ | ម៉ាឡេស៊ី | ៩ | | ៩ | | | | | ៩ | | | | ៨ | ១ | | | | | | |
| 5 | វៀតណាម | ៣១ | | | | | | | | ៣១ | | | | | | | | | | |
| 6 | ស្រី៊ | | | | | | | | | | | | | | | | | | | |
| 7 | ចិន | | | | | | | | | | | | | | | | | | | |
| | សរុប | ៤០ | ០ | ៩ | ០ | | ០ | | ៩ | ៣១ | | ០ | ៨ | ១ | ០ | ០ | ០ | ០ | ០ | ០ |

# ឧបសម្ព័ន្ធទី១

## ការងារផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ភូមិ-ឃុំមានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ។ | ស្នងការដ្ឋាននគរបាលខេត្ត ស្វាយរៀង និងកំពង់ចាម | 12 លើក | 222 នាក់ | 138 នាក់ |
| | | លេខាធិការដ្ឋានខេត្តបានបើកវេទិការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងផលវិបាកនៃការធ្វើចំណាក់ស្រុកខុសច្បាប់   ការកេងប្រវ័ញ្ចពលកម្មកុមារ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 20 លើក | 1,321 នាក់ | 726 នាក់ |
| | | ក្រុមការងារថ្នាក់ស្រុក បានសហការជាមួយអង្គការ WVC គម្រោង PADEE បានផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 5 លើក | 279 នាក់ | 150 នាក់ |
| 2 | កណ្តាល | មន្ទីរកិច្ចការនារី  បានផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើជួញដូរ ស្ត្រី និងកុមារ ដល់ប្រជាពលរដ្ឋនៅក្នុងឃុំទាំង០៨ ។ | ក្រសួងកិច្ចការនារីខេត្ត | 1 លើក | 1,663 នាក់ | 755 នាក់ |
| | | ក្រុមការងារថ្នាក់ក្រុង ស្រុក ភូមិ ឃុំ សង្កាត់បានសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលនិងអាជ្ញាធរមូលដ្ឋានស្រុកធ្វើការផ្សព្វផ្សាយលក្ខណៈសម្បត្តិទាំង០៩យ៉ាង ស្តីពីគោល នយោបាយ ភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ ឲ្យយល់អំពីការជួញដូរមនុស្ស និងការធ្វើចំណាក់ស្រុកខុសច្បាប់ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 32 លើក | 3,812 នាក់ | 1,884 នាក់ |
| 3 | កំពត | ថ្នាក់ដឹកនាំខេត្ត សហការជាមួយកិច្ចការនារី មន្ទីអង្គភាពពាក់ព័ន្ធក្នុងក្រុមការងារទាំង ៦ និងក្រុង ស្រុក ធ្វើការផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្រី និងកុមារ ការធ្វើចំណាក់ស្រុកប្រកបដោយសុវត្ថិភាព ក្នុងវេទិការសាធារណៈនៅតាមស្រុកបានចំនួន ៣លើក (ស្រុកអង្គជ័យ ស្រុកកំពង់ត្រាច ក្រុងកំពត ) | លេខាធិការដ្ឋាន គ.ខ.ប.ជ | 3 លើក | 985 នាក់ | 304 នាក់ |
| 4 | តាកែវ | បានធ្វើវេទិកាសាធារណៈ ភូមិ-ឃុំមានសុវត្ថិភាព ដែលមានសមាសភាពចូលរួមមន្ត្រីរាជការ អង្គការសង្គមស៊ីវិល ,កងកម្លាំងប្រដាប់អាវុធ ,អាជ្ញាធរ ភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 80 លើក | 4,948 នាក់ | 1,670 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 5 | កែប | ក្រុមការងារលេខាធិការដ្ឋាន គ ខ ប ជ ខេត្ត បានធ្វើការបញ្ជ្រាបការធ្វើចំណាក់ស្រុកដោយខុសច្បាប់ ជូនដល់ប្រជាពលរដ្ឋ និងការផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សតាមរយៈវេទិការផ្សព្វផ្សាយស្តីពីគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព | គណៈកម្មាធិការ គ.ខ.ប.ជ | 17 លើក | 2,637 នាក់ | 1,628 នាក់ |
| 6 | កំពង់ស្ពឺ | ក្រុមការងារលេខាធិការដ្ឋាន គ ខ ប ជ ខេត្ត បានសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលនិងអាជ្ញាធរមូលដ្ឋានក្រុងច្បារមន ស្រុកសំរោងទង បានចុះផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និង ប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អធិការដ្ឋាននគរបាលនិងអាជ្ញាធរមូលដ្ឋានក្រុង ស្រុក | 2 លើក | 225 នាក់ | 114 នាក់ |
| | | ក្រុមការងារលេខាធិការដ្ឋាន គ ខ ប ជ ខេត្ត បានសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលនិងអាជ្ញាធរមូលដ្ឋានស្រុកថ្ពង ស្រុកឧដុង្គ បានចុះផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និង ប្រជាពលរដ្ឋ ។ | | 3 លើក | 660 នាក់ | 258 នាក់ |
| 7 | កំពង់ឆ្នាំង | ក្រុមការងារលេខាធិការដ្ឋាន គ ខ ប ជ ខេត្តបានសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលនិងអាជ្ញាធរមូលដ្ឋានស្រុកធ្វើការផ្សព្វផ្សាយលក្ខណៈសម្បត្តិទាំង០៩យ៉ាង ស្តីពីគោល នយោបាយ ភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ ឲ្យយល់អំពីការជួញដូរមនុស្ស និងការធ្វើចំណាក់ស្រុកខុសច្បាប់ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អាជ្ញាធរមូលដ្ឋាន | 235 លើក | 33,228 នាក់ | 19,462 នាក់ |
| | | បានចុះផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការការពារជនរងគ្រោះ និងច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅភូមិព្រៃលាក់នាង ឃុំជ្រៃ បាក់ ឃុំគោកបន្ទាយ ភូមិពពេលពក ស្រុករលាប្អៀរ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អាជ្ញាធរមូលដ្ឋាន ស្រុករលាប្អៀរ | 2 លើក | 100 នាក់ | 62 នាក់ |
| 8 | សៀមរាប | បានចុះផ្សព្វផ្សាយអំពីច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាក់ស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅស្រុកស្វាយលើ(ឃុំបឹងមាលា០២លើក ឃុំស្វាយលើ០៣លើក តាសៀម ០២លើក ឃុំកន្ទួត០៤លើក) ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អាជ្ញាធរមូលដ្ឋាន ស្រុកស្វាយលើ | 11 លើក | 682 នាក់ | 422 នាក់ |
| | | បានចុះផ្សព្វផ្សាយអំពីច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាក់ស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅស្រុកស្រីស្នំ និងស្រុកក្រឡាញ់ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 55 នាក់ | គ្មាន នាក់ |
| | | បានចុះផ្សព្វផ្សាយអំពីច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាក់ស្រុកដោយសុវត្ថិភាព និងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅស្រុកសូទ្រនិគម ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អាជ្ញាធរមូលដ្ឋាន ស្រុកសូទ្រនិគម | 18 លើក | 810 នាក់ | 750 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 9 | ឧត្តរមានជ័យ | គណៈកម្មាធិការពិគ្រោះយោបល់បានសហការការិយាល័យជំនាញនគរបាល ស្រុក សំរោង អន្លង់វែង , ត្រពាំងប្រាសាទ , បន្ទាយអំពិល, ចុងកាល និងអាជ្ញាធរមូលដ្ឋាន បានចុះផ្សព្វផ្សាយអំពីច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ដល់ ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 35 នាក់ | 20 នាក់ |
| 10 | បាត់ដំបង | បានចុះផ្សព្វផ្សាយនិងវេទិកាសាធារណៈស្តីពីការអនុវត្តន៍គោលនយោបាយភូមិ /ឃុំមានសុវត្ថិភាព ដល់កងកំលាំងប្រដាប់អាវុធ មន្ត្រី រាជការ និងប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 225 លើក | 16,404 នាក់ | 8,574 នាក់ |
| 11 | ពោធិ៍សាត់ | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមភូមិឃុំមានសុវត្ថិភាព ក្រុងពោធិ៍សាត ស្រុកក្រគរ កណ្តៀង ភ្នំក្រវាញ បាកាន វាលវែង អង្គការសម្រាលទុក្ខមនុស្សជាតិបានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងស្រុកវាលវែង ស្តីពីច្បាប់ប្រឆាំងការជួញដូរមនុស្ស និងការធ្វើចំណាក់ស្រុក ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 192 លើក | 46,497 នាក់ | 25,654 នាក់ |
| | | បានបញ្ជ្រាបវេទិកាសាធារណៈ ភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ ស្រុកបាកាន ស្រុកក្រវាញស្តីពីច្បាប់ប្រឆាំងការជួញដូរមនុស្ស និងការធ្វើចំណាក់ស្រុក ។ | | 17 លើក | 772 នាក់ | 426 នាក់ |
| 12 | កំពង់ចាម | ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាមបានធ្វើការផ្សព្វផ្សាយ គោលនយោបាយភូមិឃុំ មានសុវត្ថិភាព ស្តីពីចំណាក់ស្រុកដោយសុវត្ថិភាព ដល់កងកំលាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 288 លើក | 16,500 នាក់ | 9,111 នាក់ |
| 13 | ត្បូងឃ្មុំ | ផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈស្តីពីភូមិមានសុវត្ថិភាព ការធ្វើចំណាក់ស្រុកដោយសុវត្ថិភាពនិងការទប់ស្កាត់ការជួញដូរមនុស្ស (ស្រុកក្រូចឆ្មារ ០២លើក ស្រុកត្បូងឃ្មុំ ២៧លើក) | ស្នងការដ្ឋាននគរបាលខេត្ត | 26 លើក | 1,687 នាក់ | 666 នាក់ |
| | | មន្ទីរអប់រំយុវជន និងកីឡាបានផ្សព្វផ្សាយស្តីពីការបង្ក្រាបការជួញដូរមនុស្សអំពោះធ្វើអាជីវកម្មផ្លូវភេទ និងការជួញដូរកំលាំងពលកម្ម ចំណាក់ស្រុកច្បាប់ទៅក្រៅប្រទេស ដល់ សិស្សានុសិស្ស នៅក្នុងវិទ្យាល័យ ហ៊ុន សែន ត្រពាំងឫស្សី ដែលមានលោកគ្រូ អ្នកគ្រូ ។ | មន្ទីរអប់រំ យុវជននិងកីឡា | 2 លើក | 42 នាក់ | 18 នាក់ |
| 14 | ប៉ៃលិន | ថ្ងៃទី ២៧ មេសា ឆ្នាំ ២០១៦ នៅសាលប្រជុំក្រុងប៉ៃលិនបានប្រជុំផ្សព្វផ្សាយ អំពីការយល់ដឹងការធ្វើចំណាក់ស្រុកនិងការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់កងកំលាំងប្រដាប់អាវុធ មន្ត្រី រាជការ និងប្រជាពលរដ្ឋ ។ | គណៈកម្មាធិការ គ.ខ.ប.ជ | 1 លើក | 21 នាក់ | 11 នាក់ |
| 15 | កំពង់ធំ | ក្រុមការងារលេខាធិការដ្ឋានបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស រយៈពេល០៥ថ្ងៃសៀមរាប ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | | |

| | | | | | | |
|---|---|---|---|---|---|---|
| 16 | ក្រចេះ | មន្ទីរកិច្ចការនារីខេត្ត បានចុះផ្សព្វផ្សាយស្តីពីសិទ្ធកុមារ និងការទប់ស្កាត់ការជួញដូរមនុស្ស ដល់កងកំលាំងប្រដាប់អាវុធ មន្ត្រី រាជការ និងប្រជាពលរដ្ឋ ។ | មន្ទីរកិច្ចការនារីខេត្ត អង្គការ | 2 លើក | 139 នាក់ | 104 នាក់ |
| 17 | ស្វាយរៀង | បានចុះផ្សព្វផ្សាយសេចក្តីណែនាំលេខ ០០៥របស់អគ្គស្នងការនគរបាលជាតិឱ្យម្ចាស់អាជីវកម្មសង្ស័យថាមានបទល្មើសផ្លូវភេទដូចជា ខារ៉ាអូខេ សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួលម៉ាស្សា កោសជប់ ស្រុកចន្ទ្រា និងក្រុងបាវិត បានចុះផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការងារពាក់ព័ន្ធគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ។ | ស្នងការដ្ឋាននគរបាលខេត្ត | 200 លើក | 18,002 នាក់ | 1,100 នាក់ |
| 18 | ព្រះសីហនុ | ក្រុមការងារ គ.ខ.ប.ជ បានសហការជាមួយអាជ្ញាធរក្រុង/ស្រុក តាមរយៈការផ្សព្វផ្សាយគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព និងអង្គការដៃគូរ ផ្សព្វផ្សាយអំពីការរំលោភបំពានផ្លូវភេទ បានធ្វើអាជីវកម្មផ្លូវភេទ លើស្ត្រីនិងកុមារ ការចំណាក់ស្រុកខុសច្បាប់ បានចំនួន០៦លើក | គណៈកម្មាធិការ គ.ខ.ប.ជ | 6 លើក | 166 នាក់ | 79 នាក់ |
| | | ក្រុមការងារបានចូលរួមផ្សព្វផ្សាយវេទិកាសាធារណៈភូមិឃុំមានសុវត្ថភាព ដល់កំលាំងសមត្ថកិច្ច មន្ត្រីរាជការ អង្គការ សង្គមស៊ីវិល លោកគ្រូ /អ្នកគ្រូ និងប្រជាជន ។ | | 11 លើក | 773 នាក់ | 396 នាក់ |

សកម្មភាពសរុបចំនួន: 1,414 លើក

មនុស្សសរុបចំនួន: 152,665 នាក់

ស្រីសរុបចំនួន: 74,482 នាក់

# ឧបសម្ព័ន្ធទី២

## ការទារបង្ការទប់ស្កាត់

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | កន្លែង/គោលដៅ | មនុស្សសរុប | ស្ត្រី |
|---|---|---|---|---|---|---|
| 1 | កោះកុង | ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនសហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលស្ទាចមានជ័យ បានឃាត់ប្រជាពលរដ្ឋដែលបានប្រុងឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃនៅចំណុច ភូមិបឹងឃុនឆាង ,សង្កាត់ស្ទាចមានជ័យ ,ក្រុងខេមរភូមិន្ទ ក្នុងស្រុកស្រែអំបិល ខេត្តកោះកុង ។ | ស្នងការនគរបាលខេត្ត | 1 លើក | 49 នាក់ | គ្មាន នាក់ |
| 3 | កំពត | បានកោះអញ្ជើញម្ចាស់ផ្ទះសំណាក់ ផ្ទះជួល កន្លែងម៉ាស្សា ជប់ខ្យល់ ខារ៉ាអូខេ ១២នាក់ដើម្បីសហការក្នុងការទប់ស្កាត់ការបញ្ចាំងវីដេអូអាសអាភាស ដើម្បីបង្ការទប់ស្កាត់ និងកាត់បន្ថយការរំលោភសេពសន្ថវៈលើស្ត្រីនិងកុមារ | ស្នងការនគរបាលខេត្ត | 1 លើក | 12 នាក់ | គ្មាន នាក់ |
| 4 | ពោធិសាត់ | ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិបានបង្ក្រាបបទល្មើសសញ្ចារកម្ម ទាក់ទងនឹងពេស្យាចារកុមារ នៅបន្ទាយដីលើ សង្កាត់បន្ទាយដី ក្រុងពោធិ៍សាត់ និងបានជួយ ជនរងគ្រោះបានប្រគល់អោយអង្គការក្តីសង្ឃឹមនិងយុត្តិធម៌ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 6 នាក់ | គ្មាន នាក់ |
| 5 | ស្វាយរៀង | បន្តផ្សព្វផ្សាយអំពីសេចក្តីណែនាំលេខ០០៥ របស់អគ្គស្នងការនគរបាលជាតិ ដល់ម្ចាស់អាជីវកម្មសង្ស័យពាក់ព័ន្ធបទល្មើសផ្លូវភេទ ទៅដល់បណ្តាអាជីវកម្ម ខារ៉ាអូខេ ផ្ទះសំណាក់ ផ្ទះជួល ម៉ាស្សាកោសជប់ ផ្ទះលក់ការហ្វេ និងជួលលក់វីស៊ីឌី ធ្វើនៅក្រុងស្វាយរៀង និងក្រុងបាវិត បានចុះផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធញ្ញរើអាជីវកម្មផ្លូវភេទ ការធ្វើចំណាក់ស្រុក ដល់មន្ត្រីនគរបាលយុត្តិធម៌ | ស្នងការដ្ឋាននគរបាលខេត្ត | 6 លើក | 48 នាក់ | 39 នាក់ |

សកម្មភាពសរុប: 9 លើក

មនុស្សសរុបចំនួន: 115 នាក់

ស្រីសរុបចំនួន: 39 នាក់

# តារាងឧបសម្ព័ន្ធទី៧
# ការងារដឹកនាំសម្របសម្រួល

| លរ. | អង្គភាព | សកម្មភាព | លើក | អ្នកពាក់ព័ន្ធ |
|---|---|---|---|---|
| ១ | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | -ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ បានដឹកនាំកិច្ចប្រជុំ ស្តីពីការពិនិត្យផ្ទៀងផ្ទាត់របាយការណ៍ត្រីមាសរបស់ ក្រុមជំនួយកិច្ចការទាំង៦ ឡើងវិញ មុននឹងដាក់បញ្ចូលទៅក្នុងរបាយការណ៍ត្រីមាសថ្នាក់ជាតិ និងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០១៦ របស់ក្រុមនីមួយៗ ។<br>-ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សារវាងគណៈកម្មការការពារកុមារថ្នាក់ ជាតិ និងបណ្តាញអង្គការសង្គមស៊ីវិល (CSO Consortium) រៀបចំដោយ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បី កុមារ នៅទីស្តីការក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ។<br>-ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ បានជួបប្រជុំពិភាក្សាផ្ទៃក្នុងរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តន៍ របស់ក្រុមជំនួយកិច្ចការទាំង៦ ដោយអនុលោមតាមផែនការថ្នាក់ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០១៤-២០១៨ ។ | ០៣ លើក | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| | | - លិខិតរបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ៖ លិខិតចេញ (១០ច្បាប់) លិខិតចូល (០៤ច្បាប់) ។<br>- លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ៖ លិខិតចេញ (១៨ច្បាប់) លិខិតចូល (០៩ច្បាប់) បេសកកម្មគ្មាន បង្គាប់ការ (គ្មាន) ទិដ្ឋាការធ្វើដំណើរ (គ្មាន) ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី ធ្វើរបាយការណ៍ប្រចាំថ្ងៃ និងខែ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ធ្វើកំណត់ហេតុនៅរៀងរាល់កិច្ចប្រជុំ រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី/ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា ។<br>- ប្រមូលរបាយការណ៍ប្រាំខែ និងរបាយការណ៍ត្រីមាសទី១ ឆ្នាំ២០១៦ តាមបណ្តាអន្តរក្រសួង ស្ថាប័ន និង រាជធានី/ខេត្តទាំង២៥ និងបញ្ចប់បូកសរុបរបាយការណ៍ខែមីនា ឆ្នាំ២០១៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ<br>- បូកសរុបរបាយការណ៍ត្រីមាសទី១ ឆ្នាំ២០១៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បានទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ លើសំណើសុំថវិការៀបចំកិច្ចប្រជុំ | ១៣ លើក | លេខាធិការដ្ឋាន គ.ជ.ប.ជ |
| | | -ថ្នាក់ជាតិ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ និងលើសំណើសុំឯកសណ្ឋានថ្នាក់ អគ្គលេខាធិការរង ០៤រូប នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បានទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើសំណើសុំថវិកាសម្រាប់រៀបចំកិច្ចប្រជុំជាមួយអន្តរក្រសួង ។<br>- បង្កើតទម្រង់បញ្ចេញ-បញ្ចូលឃ្លាំង សម្រាប់ប្រើប្រាស់ក្នុងឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បន្តរៀបចំកែសម្រួលផែនការថវិកាឆ្នាំ២០១៦ សម្រាប់ផ្តល់ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ | | |

| | | | | |
|---|---|---|---|---|
| | | - បន្តរក្សាទុករូបភាព និងសកម្មភាពថ្នាក់ជាតិ និងក្រោមជាតិ ចូលក្នុងបណ្ណាសារ WiKi ។ | | |
| | | - បន្តដំណើរការបង្កើត Database គ្រប់គ្រងទំព័រ facebook របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ ។<br>- ស្រាវជ្រាវព័ត៌មានពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មាន និង Comment ផ្សេងៗ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សលើទំព័រ facebook ។<br>- ប្រមូលរបាយការណ៍តាមបណ្តារាជធានី/ខេត្ត តាមប្រព័ន្ធ Telegram និង Gmail ។ | | លេខាធិការដ្ឋាន គ.ជ.ប.ជ |
| | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | - ថ្ងៃទី ០៥-០៧ ខែមេសា ឆ្នាំ២០១៦ បានចូលរួមសិក្ខាសាលាជាមួយអង្គការពលកម្មអន្តរជាតិ IOM ស្តីពីការផ្លាស់ប្តូរវិធីសាស្ត្រ នៅភោជនីយដ្ឋានទន្លេបាសាក់ ។<br>- បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំធ្វើរបាយការណ៍ត្រីមាសទី១ ឆ្នាំ២០១៦ របស់ ក្រុមការងារបង្ការទប់ស្កាត់ ។<br>- បានពិនិត្យ និងតាមដានព័ត៌មានជាប្រចាំពីសកម្មភាពការបើកវេទិកាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមបណ្តារាជធានី/ខេត្ត តាមរយៈតេឡេក្រាម ។ | ០៣ លើក | ក្រុមជំនួយកិច្ចការ បង្ការ ទប់ស្កាត់ |
| | | - ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៦ បានចូលរួមប្រកាសសមាសភាពក្រុមការងារការពារជនរងគ្រោះ នៅក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។<br>- ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ បានចុះបេសកកម្មទៅស្រុកម៉ាឡៃ ត្រួតពិនិត្យឯកសារក្លែងក្លាយដែលក្រុមហ៊ុន បានផ្តល់ឲ្យពលករ<br>- ថ្ងៃទី០៧-០៨ ខែមេសា ឆ្នាំ២០១៦ បានចូលរួមសិក្ខាសាលា ស្តីពីការលុបបំបាត់រាល់ទម្រង់ការរើសអើងចំពោះ ស្ត្រីពិកា ដែលរៀបចំដោយក្រសួងកិច្ចការនារី នៅសណ្ឋាគារកាំបូឌីយ៉ាណា ។ | ០៤ លើក | ក្រុមជំនួយកិច្ចការ ការពារជនរងគ្រោះ |
| | | - ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ បានពិភាក្សាការងារ ការធ្វើផែនការលម្អិត ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើ ជួញដូរមនុស្ស ។ | | |
| | | - តាមដានសកម្មភាពការងារ និងប្រមូលរបាយការណ៍ ពាក់ព័ន្ធនឹងការងារអនុវត្តច្បាប់ នៅតាមបណ្តារាជធានី/ខេត្ត និងទំនាក់ទំនងសហការជាមួយក្រុមការងារអនុវត្តច្បាប់ ដែលដឹកនាំដោយអគ្គស្នងការនគរបាលជាតិ ។ | ០១ លើក | ក្រុមកាងារអនុវត្ត ច្បាប់ |
| | | - ថ្ងៃទី០៥-០៦ ខែមេសា ឆ្នាំ២០១៦ បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីមធ្យោបាយទាក់ទង ដើម្បី អភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។<br>- ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ បានជួបពិភាក្សាជាមួយ ឯកឧត្តម ពេញ វិបុល អគ្គលេខាធិការដ្ឋានរង នៃអគ្គ នាយដ្ឋានកិច្ចការអយ្យការនៅក្រសួងយុត្តិធម៌ ។<br>- ជំរុញក្រុមការងារយុត្តិធម៌ ដើម្បីផ្តល់របាយការត្រីមាសទី១ ស្តីពីការចោទប្រកាន់ និងការកាត់ទោសជនល្មើស ពាក់ព័ន្ធអំពើជួញដូរមនុស្ស ។<br>- បានបញ្ចប់របាយការត្រីមាសទី១ ជាមួយក្រុមការងារយុត្តិធម៌ ។<br>- រៀបចំមេរៀនសម្រាប់ចុះបណ្តុះបណ្តាលនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ។ | ០៥ លើក | ក្រុមជំនួយកិច្ចការ យុត្តិធម៌ |
| | | - ថ្ងៃទី២០-២៥ ខែមេសា ឆ្នាំ២០១៦ បានចូលរួមអង្គប្រជុំអន្តរកាលនៃវេទិកាតំបន់អាស៊ានលើកទី១៤ ស្តីពី "**ការប្រយុទ្ធប្រឆាំងអំពើភារវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន**" និងចូលរួមអង្គសិក្ខាសាលា ស្តីពី "**សេចក្តីព្រាងលិខិតតូបករណ៍ ប្រឆាំងការរត់ពន្ធអាវុធធុនតូច និងធុនស្រាល**" | ០២ លើក | ក្រុមជំនួយកិច្ចការ |

| | | | | |
|---|---|---|---|---|
| | | - នៅខេត្តសៀមរាប ។<br>- ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំលើកទី៣០ នៃប្រធានអង្គភាពឯកទេសប្រឆាំងអំពើជួញដូរ មនុស្សរបស់អាស៊ាន ដែលមានប្រទេសជាសមាជិកអាស៊ានចំនួន៦ រួមមានប្រ៊ុយណេ កម្ពុជា ហ្វីលីពីន សឹង្ហបុរី ថៃ និងវៀតណាម តំណាងអគ្គលេខាធិការដ្ឋានអាស៊ាន និងតំណាងគម្រោង AAPTIP នៅសណ្ឋាគារសុខាវ៉េស៊ីដង់ រាជធានីភ្នំពេញ ។ | | ទំនាក់ទំនងអន្តរជាតិ |
| | | - ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ បានអញ្ជើញលោក នាក់ ហេង ប្រធានសមាគមន៍ដឹកជញ្ជូនការងារក្រៅប្រព័ន្ធ និង ក្រុមប្រឹក្សាភិបាលសភាសម្ព័ន្ធសហជីពកម្ពុជា (NACC) មកសាកសួរបំភ្លឺ អំពី Comment របស់លោកនៅក្នុង facebook របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ សូមឲ្យលោកជំទាវជួយពន្លឿនការផ្តល់លិខិតឆ្លង ដែនដល់ពលករ ព្រោះពេលនេះថៃកំពុងតែឲ្យពលករបន្តប្រើប័ណ្ណស៊ីជម្ពូ តម្លៃជិតប្រាំមួយពាន់បាត ជាលទ្ធផល | ០៩ លើក | ក្រុមទំនួយកិច្ចការទេសន្តរប្រវេសន៍ |
| | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | នេះជាការពិតព្រោះលោកបានទទួលសំណូមពរពីពលករកម្ពុជាជាច្រើននាក់ ពេលលោកចុះសួរសុកទុកនៅខេត្ត រ៉ាក់យ៉ង ប្រទេសថៃ ។ ក្នុងនាមសហជីព សុំឲ្យជួយអន្តរាគមន៍មក ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីជួយផ្តល់លិខិតឆ្លង ដែន ដែលស្របច្បាប់ដល់ពួកគាត់ឲ្យបានឆាប់ ព្រោះចាប់តាំងពីក្រុមហ៊ុនការងារចល័តអន្តរក្រសួងទី៧ចុះ ទៅខេត្តរ៉ាក់យ៉ង ក្នុងខែមេសា ឆ្នាំ២០១៥ ដើម្បីចុះបញ្ជី និងប្រមូលថ្លៃសេវាក្នុងម្នាក់ៗ ១.៤០០បាត ពីពួកគាត់ដើម្បីធ្វើលិខិតឆ្លងដែនជូនមក រហូតដល់ពេលនេះនៅមិនទាន់ឆ្លើយតបជូនពួកគាត់នៅឡើយ ទើបថៃឲ្យពលករកម្ពុជាបន្តប្រើប័ណ្ណស៊ីជម្ពូ ។<br>- ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ លោក ថៅ សុខ តំណាងអង្គការលីកាដូ បានទទួលទូរស័ព្ទសុំឲ្យយើងជួយអន្តរាគមន៍ដល់នារីរងគ្រោះ០២ នាក់ៈ ឈ្មោះ ប្រាក់ សោភ័ណ្ឌ អាយុ៣០ឆ្នាំ ទីលំនៅក្នុងខេត្តតាកែវ និងឈ្មោះ ចាន់ ស៊ីថា អាយុ២២ឆ្នាំ ទីលំនៅក្នុងខេត្តកណ្តាល ដែលបានចាញ់បោកមជ្ឈមណ្ឌលជំនាញថៃទាំកម្ពុជា-ជប៉ុន ទីតាំងផ្ទះលេខ៤៨០ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ក្នុងម្នាក់ៗ អស់ចំនួន៤.០០០ ដុល្លា អាមេរិក ពេលចុះឈ្មោះដើម្បីទៅធ្វើការនៅប្រទេសជប៉ុន តាំងពីខែកញ្ញា ឆ្នាំ២០១៥ ។ ម្ចាក់មជ្ឈមណ្ឌលឈ្មោះ ឡាច សុភិន ជាអ្នកទទួលប្រាក់ពីនារីទាំងពីរនាក់ (ដោយមានធ្វើកិច្ចសន្យាត្រឹមត្រូវ និងសន្យាតែរយៈពេល០៣ខែនឹងបានទៅ) ឯនាយកជំឈ្មោះ សុខ ពិសិទ្ធ (ឬ សុខ ប្រាសិទ្ធ) ធ្វើការនៅទីស្តីការគណៈរដ្ឋមន្ត្រី តែរហូតដល់ថ្ងៃនេះនៅពុំទាន់បានទៅធ្វើការតាមកិច្ចសន្យានៅឡើយ ហើយទាប្រាក់វិញក៏មិនបាន ។ ករណីនេះយើងបាន ទំនាក់ទំនងទៅឈ្មោះ ប្រាក់ សោភ័ណ្ឌ ឲ្យនាងមកដាក់ពាក្យបណ្តឹង ហើយនារីរងគ្រោះទាំងពីរ បានដាក់ពាក្យ បណ្តឹងនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ អំពបទឆបោក ។<br>- ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ បានណែនាំឈ្មោះ បិត បេន ភេទស្រី អាយុ៣៥ឆ្នាំ រស់នៅភូមគង្គា ឃុំស្នោរ ស្រុកព្រៃកប្បាស ខេត្តតាកែវ ឲ្យដាក់ពាក្យបណ្តឹងនៅនាយដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ករណីក្មួយស្រីរបស់គាត់ ឈ្មោះ ស្រេង ចាន់ធូ អាយុ ២៧ឆ្នាំ រស់នៅភូមិស្រុកជាមួយគ្នា បានចាញ់បោកមេខ្យល់ស្រី (មិនស្គាល់អត្តសញ្ញាណម្នាក់) នាំទៅរៀបការ នៅក្នុងខេត្តគួនមិញ ប្រទេសចិន តាំងពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣ ។<br>- ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ បានចុះសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្នើសុំរបាយ | | ក្រុមទំនួយកិច្ចការទេសន្តរប្រវេសន៍ |

| | | | | |
|---|---|---|---|---|
| | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | - ការណ៍ត្រីមាសទី១ ឆ្នាំ២០១៦ របស់ក្រុមការងារទេសន្តរប្រវេសន៍ រួមទាំងលិខិតូបករណ៍អន្តរជាតិ ពាក់ព័ន្ធការ ការពារ និងលើកកម្ពស់សិទ្ធិពលករ ទេសន្តរប្រវេសន៍ការងារនៅក្រៅប្រទេស ។<br>- ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ បានទំនាក់ទំនងលោក អ៊ុក រ៉ាវុធ ប្រធានការិយាល័យហត្ថពលកម្ម និងមុខរបរ យកសៀវភៅរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៥ ដែលបានចុះហត្ថលេខា ជាផ្លូវការរួច ។<br>- បានជូនដំណឹងទៅលេខាធិការដ្ឋាន (គ.ខ.ប.ជ) ខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ ឲ្យជូនដំណឹងបន្តទៅក្រុមគ្រួសារ នារីរងគ្រោះ០២នាក់ ដែលត្រូវបានស្ថានទូតកម្ពុជាប្រចាំប្រទេសចិន និងប្រទេសម៉ាឡេស៊ី ជួយសង្គ្រោះ និងបានទៅទទួលដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញ ១. ឈ្មោះ វេន ផល្លី អាយុ២១ឆ្នាំ រស់នៅក្នុងស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ ត្រូវបានប្តីចិនធ្វើបាបបិទសិទ្ធិសេរីភាព និងពលការិនីឈ្មោះ យូ ចន្ថា រស់នៅឃុំចង្រុង ស្រុកចិត្របូរី ខេត្តក្រចេះ ទៅធ្វើការបម្រើតាមផ្ទះនៅម៉ាឡេស៊ី តាមរយៈមេខ្យល់កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៣ ។ អ្នក ទាំងពីរបានវិលត្រឡប់មកផ្ទះវិញនៅថ្ងៃទី០១ និងទី១២ ខែមេសា ឆ្នាំ២០១៦ ។<br>- បានបូកសរុបប្រចាំថ្ងៃនូវចំនួនពលករចំណាកស្រុកខុសច្បាប់ ដែលអាជ្ញាធរថៃពញ្ជូនមកកម្ពុជាវិញ (ពីថ្ងៃទី០១ ដល់៣០ ខែមេសា ឆ្នាំ២០១៦) សរុបចំនួន **៦.៣២៥**នាក់ (ស្រី២.០៨៤នាក់ កុមារ៥០០នាក់)ក្នុងនោះ៖<br>• តាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ចំនួន ៥.៧០៤នាក់ (ស្រី**១.៨៩៥**នាក់ កុមារ**៤៣២**នាក់)<br>• តាមច្រកសំពៅលូន ខេត្តបាត់ដំបង ចំនួន **៥៩៦**នាក់ (ស្រី**១៨១**នាក់ កុមារ**៦០**នាក់)<br>• តាមច្រកភ្នំដី ខេត្តបាត់ដំបង ចំនួន **២៣**នាក់ (ស្រី**០៨**នាក់ កុមារ**០៨**នាក់)<br>- តាមច្រកអានសេះ ខេត្តព្រះវិហារ ចំនួន **០២**នាក់ ។ | | ក្រុមទំនួយកិច្ចការទេសន្តរប្រវេសន៍ |
| | បន្ទាយមានជ័យ | - បានរៀបចំទទួល និងជួបប្រជុំសំណេះសំណាលជាមួយ គណៈប្រតិភូ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស គ.ជ.ប.ជ ដឹកនាំដោយលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ។ | ១លើក | គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត មន្ទីរសង្គមកិច្ច |
| | បាត់ដំបង | - បានចូលរួមសិក្ខាសាលា បិទគម្រោងបំផុសចលនាសង្គម ប្រឆាំងនឹងពលកម្មកុមារ ដែលមានអ្នកចូលរួមចំនួន៧០នាក់ រៀបចំដោយ អង្គការទស្សនៈ WVC នៅសាលប្រជុំសាលាស្រុកស្ទឹងសង្កែ ។<br>- បានចូលរួមប្រជុំ ស្តីពីការរៀបចំផែនការសមាហរណកម្មកុមារ៣០% ចេញពីមណ្ឌលថែទាំកុមារ មានអ្នកចូលរួមចំនួន<br>**៧៣**នាក់ ស្រីចំនួន**២៦**នាក់ នៅសាលាខេត្តបាត់ដំបង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត សហការជាមួយអង្គការ Unicef និងអង្គការទំនុកចិត្តកុមារកម្ពុជា ។<br>- បានចូលរួមប្រជុំជាមួយអង្គការ HAGAR និងអង្គការ WVC ក្នុងការផ្ទេរជនរងគ្រោះដោយសារអំពើជួញដូរមនុស្សចំនួន០២នាក់ ពីអង្គការ WVC ទៅអង្គការ HAGAR គ្រប់គ្រងបន្ត (ករណីទី០១ នៅភូមិបឹងអូរជាង ឃុំកំរៀង ស្រុកកំរៀង)(ករណីទី០២ នៅភូមិកសិកម្ម ឃុំតាមឺន ស្រុកថ្មគោល ) ។<br>- បានចូលរួមប្រជុំជាមួយអង្គការ WVC ចុះបិទករណី ជនរងគ្រោះដោយសារអំពើជួញដូរមនុស្សចំនួន**១១**ករណី (គឺនៅស្រុករតនមណ្ឌល | ៥លើក | ក្រុងបាត់ដំបង និង ស្រុកសង្កែ |

| | | | | |
|---|---|---|---|---|
| | | ០៣ករណី ស្រុកបាណន់០៤ករណី និងស្រុកបវេល០៤ករណី ) ។<br>- បានចាត់បញ្ជូនមន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្សចំនួន០៦រូប(ស្រី) ទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញស៊ើបអង្កេតអំពើជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា រៀបចំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស សហការជាមួយ អង្គការ AAPTIP ដែលមានសិក្ខាកាមចូលរួមចំនួន២៥នាក់(ស្រី) | | ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង |
| | ព្រះវិហារ | - ស្នងការដ្ឋាននគរបាលខេត្ត បានបញ្ជូនមន្ត្រីជំនាញចំនួន០៣នាក់(ស្រី) ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញស៊ើបអង្កេតអំពើជួញដូរមនុស្សសម្រាប់មន្ត្រីនគរបាលស្ត្រីក្នុងប្រទេសកម្ពុជា នៅសណ្ឋាគារអង្គរ ផារ៉ាដាយ ខេត្តសៀមរាប ។ | ១លើក | ស្នងការដ្ឋាននគរបាលខេត្ត |
| | កំពង់ធំ | - ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានអញ្ជើញក្រុមការងារទាំង០៦ ដើម្បីពិភាក្សាអំពីវិធីសាស្ត្រ គឺធ្វើយ៉ាងណាឲ្យការងារ មានប្រសិទ្ធភាព ក្នុងការអនុវត្តសកម្មភាពទទួលបានជោគជ័យរបស់ក្រុមនីមួយ ៗ និងពិភាក្សាក្នុងការបន្ថែម ឬបន្ថយសមាសភាពនៃក្រុមការងារ ដែលមានអ្នកចូលរួមចំនួន០៧ ស្រីចំនួន០៣នាក់ ។<br>- បានប្រជុំលេខាធិការដ្ឋាន និងក្រុមការងារទាំង០៦ ដោយសម្រេចឲ្យក្រុមទាំងនេះ ធ្វើការប្រជុំជាទៀងរាល់ខែ និងលេខា ធិកា ប្រជុំរាល់៣ខែម្តង មានអ្នកចូលរួមចំនួន៣២នាក់ ស្រីចំនួន០៨នាក់ ។ | ២លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត |
| | សៀមរាប | - ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានដឹកនាំកិច្ចប្រជុំចំនួន០២លើក<br>• ប្រជុំ ស្តីអំពីការបូកសរុបរបាយការណ៍ត្រីមាសទី០១ ដែលមានសមាសភាពចូលរួមចំនួន៣៤នាក់ ស្រីចំនួន១៤នាក់ នៅសាលាខេត្ត ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៦ ។<br>• ប្រជុំ ស្តីអំពីលទ្ធផលបូកសរុបរបាយការណ៍ត្រីមាសទី០១ ដែលមានសមាសភាពចូលរួមចំនួន៣៣នាក់ ស្រីចំនួន១៨នាក់ នៅសាលាខេត្ត ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ។<br>-ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានជួបពិភាក្សាការងារ ស្តីពីការអនុវត្តសកម្មភាពការងារ និងតម្រូវការចាំបាច់របស់លេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ជាមួយអង្គការ USAID និង អង្គការ WIN ROCK បានចំនួន០១លើក មានអ្នកចូលរួមចំនួន១៦នាក់ ស្រីចំនួន០៤នាក់ នៅសាលាខេត្ត ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៦ ។<br>-ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានជួបធ្វើកិច្ចសម្ភាសន៍ ជាមួយទីប្រឹក្សាវាយតម្លៃគម្រោងរបស់អង្គការទស្សនពិភពលោក ស្តីពីការអនុវត្តគម្រោង លើកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសាលាខេត្តថ្ងៃទី២១ ខែ មេសា ឆ្នាំ២០១៦ ។<br>-ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមប្រជុំត្រួតពិនិត្យ នៃការអនុវត្តច្បាប់របស់ភ្នាក់ងារនគរបាលយុត្តធម៌ នៅមន្ទីរសាលាខេត្ត ថ្ងៃទី២១ ខែ មេសា ឆ្នាំ២០១៦ ។ | ៥លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត |
| | ក្រចេះ | - ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ក្រុមលេខាធិការ ស្តីអំពីការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែមេសា ឆ្នាំ២០១៦ ដែលមានសមាសភាពចូលរួមចំនួន០៧នាក់ ស្រីចំនួន០២នាក់ ។ | ១លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត |

| | | | | |
|---|---|---|---|---|
| | កណ្តាល | -លេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ស្រុក និងឃុំទាំង១១បានប្រជុំឆ្លងរបាយការណ៍ខែមេសា ចំនួន០២លើក មានអ្នកចូលរួមចំនួន៥០នាក់ ស្រចំនួន២៤នាក់ ។<br>-ក្រុមការងារថ្នាក់ស្រុក បានប្រជុំប្រចាំខែ ដើម្បីពង្រឹងសមត្ថភាពជម្រុញឲ្យជនបង្គោលនៃឃុំទាំង១៨ បន្តសកម្មភាពធ្វើការផ្សព្វផ្សាយទប់ស្កាត់អំពើប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកខុសច្បាប់ ដល់ប្រជាពលរដ្ឋកុំឲ្យចាញ់បោកការឃោសនាជនខិលខូចមួយចំនួនតូច បានចំនួន០១លើក មានអ្នកចូលរួមចំនួន២៥នាក់ ស្រចំនួន១៩នាក់ ។<br>-មន្ទីរកិច្ចការនារី បានចូលរួមប្រជុំជាមួយមន្ត្រីគម្រោងប៉ាឌី ក្នុងការជ្រើសរើសកសិកររៀនមុខរបរក្រៅពីកសិកម្ម ដោយបាន បញ្ជ្រៀបកម្មវិធីផ្សព្វផ្សាយអំពើជួញដូរស្ត្រី និងកុមារ ដល់មន្ត្រីថ្នាក់ស្រុក ភូមិ ឃុំ បានចំនួន០១លើក មានអ្នកចូលរួមចំនួន៦៥ ស្រីចំនួន៣២នាក់ ។ | ៤លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត |
| | ស្វាយរៀង | ការិយាល័យប្រឆាំងការអំពើជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជូននាយនគរបាលចំនួន០២រូបចូលរួមសិក្ខាសាលា ស្តីពីការពង្រឹងអង្គភាពពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ និងព្រហ្មទណ្ឌ មានអ្នកចូលរួមចំនួន៩៨នាក់ ស្រីចំនួន០៧នាក់ មានការគាំទ្រដោយឆ្នោតជាតិអង់គ្លេស នៅសាលាប្រជុំសាខាកាកបាតក្រហមកម្ពុជាខេត្តស្វាយរៀង ។ | ១លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត |

សកម្មភាពសរុបចំនួន ៦០លើក